ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៩ លេខ ០១

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC

ក




ស

វ

Work Activities

ប្រចាំខែមករា ឆ្នាំ២០១៦



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | លេខទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជន | ១ |
| ២- | សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតនិងការគ្រប់គ្រងអភិវឌ្ឍន៍ព្រៃឈើជាតិ | ៣ |
| ៣- | ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំឆ្នាំ២០១៥ | ៥ |
| ៤- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១៤ |

## សេចក្តីព្រាងច្បាប់ស្តីពី

# យុត្តិធម៌អនីតិជន

កាលពីថ្ងៃទី១៧ ថ្ងៃទី២២ និងថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦ នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឆយ អូន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) និង ឯកឧត្តម **ឡាំ ជា** អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជន** ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។




ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាសហការជាមួយក្រសួងយុត្តិធម៌ ដោយមានអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិដើម្បីកុមារជាសេនាធិការ បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជន ក្នុងគោលបំណងធានាការពារសិទ្ធិ និងឧត្តមប្រយោជន៍របស់អនីតិជន គាំទ្រដល់ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មអនីតិជនទៅក្នុងសង្គម និងសហគមន៍ ព្រមទាំងធានាការពារផលប្រយោជន៍សង្គម និងសហគមន៍។

សេចក្តីព្រាងច្បាប់នេះបានដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រីម្តងរួចមកហើយ កាលពីខែមេសាឆ្នាំ២០១០ ដោយបានឆ្លងកិច្ចប្រជុំជំនាញបច្ចេកទេសដែលដឹកនាំដោយក្រុមប្រឹក្សាអ្នកច្បាប់ និងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃទីស្តីការគណៈរដ្ឋមន្ត្រី។ ដោយសេចក្តីព្រាងច្បាប់នេះមិនទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយ កិច្ចប្រជុំបច្ចេកទេសបានប្រគល់សេចក្តីព្រាងច្បាប់នេះមកក្រសួងជំនាញ ដើម្បីសិក្សា និងកែសម្រួលលើភាពខ្វះចន្លោះឡើងវិញ។ បន្ទាប់ពីកែសម្រួលតាមការណែនាំ និងឆ្លងកិច្ចប្រជុំពិគ្រោះយោបល់ជាច្រើនលើកច្រើនសារ។

## សេចក្តីព្រាងអនុក្រឹត្យស្តីពី

# ការបង្កើត និងការគ្រប់គ្រង អភិវឌ្ឍន៍ព្រៃឈើជាតិ

កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព លោកជំទាវ **គាល់ ណៃអ៊ីម** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **ជីវ សុខហាក់** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតនិងការគ្រប់គ្រងអភិវឌ្ឍន៍ព្រៃឈើជាតិ ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។




ការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតនិងការគ្រប់គ្រងអភិវឌ្ឍន៍ព្រៃឈើជាតិនេះ គឺអនុវត្តតាមច្បាប់ស្តីពីព្រៃឈើមាត្រា៦២ ដែលបានចែងថា រាជរដ្ឋាភិបាលត្រូវបង្កើតមូលនិធិមួយហៅថា **មូលនិធិអភិវឌ្ឍន៍ព្រៃឈើជាតិ** គ្រប់គ្រងចាត់ចែង និងទទួលខុសត្រូវដោយគណៈកម្មាធិការអភិវឌ្ឍន៍ព្រៃឈើជាតិ ដែលមានរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសហប្រធាន។ ការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈកម្មាធិការអភិវឌ្ឍន៍ព្រៃឈើជាតិ ត្រូវកំណត់ដោយអនុក្រឹត្យ។

បន្ទាប់ពីច្បាប់ព្រៃឈើបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០២ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ រួចមកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ បានរៀបចំលិខិតបទដ្ឋានគតិយុត្តជាច្រើន ដោយត្រូវរៀបចំតាមលំដាប់អាទិភាពនិងតាមតម្រូវការ សម្រាប់យកមកអនុវត្តឲ្យបានទាន់ពេលវេលាជាបន្តបន្ទាប់។ ដោយឡែកចំពោះការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតនិងការគ្រប់គ្រងអភិវឌ្ឍន៍ព្រៃឈើជាតិនេះ តម្រូវឲ្យអង្គភាពរដ្ឋបាលព្រៃឈើត្រូវខិតខំកៀរគរប្រភពចំណូលពីជំនួយរបស់បណ្តា

អង្គការជាតិនិងអន្តរជាតិ និងពីអំណោយសប្បុរសជន ព្រមទាំងពីប្រភពផ្សេងៗទៀត ទើបការរៀបចំអនុក្រឹត្យនេះត្រូវការពេលវេលា ដើម្បីប្រជុំពិគ្រោះយោបល់ជាមួយបណ្ដាលភាគីដែលមានការពាក់ព័ន្ធមួយរយៈពេលកន្លងមកនេះ។

ម្យ៉ាងវិញទៀត អនុលោមមាត្រា៦៣ នៃច្បាប់ព្រៃឈើ ពាក់ព័ន្ធនឹងករណីខាងលើនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំសេចក្ដីព្រាងអនុក្រឹត្យស្ដីពីការបង្កើតនិងការគ្រប់គ្រងអភិវឌ្ឍន៍ព្រៃឈើជាតិ ដែលមានចែងពីការបង្កើតគណៈកម្មាធិការអភិវឌ្ឍន៍ព្រៃឈើជាតិនៅក្នុងសេចក្ដីព្រាងអនុក្រឹត្យនេះ រួមតែម្ដង។

សេចក្ដីព្រាងអនុក្រឹត្យនេះមានគោលបំណង បង្កើតមូលនិធិអភិវឌ្ឍន៍ព្រៃឈើជាតិ និងបង្កើតគណៈកម្មាធិការអភិវឌ្ឍន៍ព្រៃឈើជាតិ ប្រមូល គ្រប់គ្រង ចាត់ចែងនិងប្រើប្រាស់មូលនិធីអភិវឌ្ឍន៍វិស័យព្រៃឈើ និងសត្វព្រៃនៅក្នុងព្រះរាជាណាចក្រកម្ពុជា កៀរគរប្រភពចំណូលពីជំនួយរបស់បណ្ដាអង្គការជាតិ និងអន្តរជាតិ និងពីអំណោយសប្បុរសជនព្រមទាំងពីប្រភពផ្សេងៗទៀត[១]។

អង្គប្រជុំបានពិនិត្យពិភាក្សាលើសេចក្ដីព្រាងនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យ ពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្ដីព្រាងនេះកាន់តែល្អ មុននឹងដាក់ឆ្លងកិច្ចប្រជុំអន្តរក្រសួងនាពេលខាងមុខ។

(១) អត្ថបទនេះដកស្រង់ពីសេចក្ដីព្រាងសេចក្ដីថ្លែងហេតុរបស់សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការបង្កើតនិងការគ្រប់គ្រងអភិវឌ្ឍន៍ព្រៃឈើជាតិ។

# ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំឆ្នាំ២០១៥



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌កម្ពុជា **ប្រចាំឆ្នាំ២០១៥**នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៦ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពី អនុប្រធាន សមាជិក សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➢ អតិផរណាឆ្នាំ២០១៥ មានអត្រាស្មើនឹង១,២% ក្នុងនោះក្រុមទំនិញដែលឡើងថ្លៃលើសអត្រានេះមានម្ហូបអាហារ ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ សំលៀកបំពាក់និងស្បែកជើង គ្រឿងសង្ហារឹមនិងសំភារៈប្រើប្រាស់ ភោជនីយដ្ឋាន ការកំសាន្ត និងវប្បធម៌។ តារាងខាងក្រោមបង្ហាញបម្រែបម្រួលសន្ទស្សន៍ថ្លៃតាមក្រុមទំនិញ។

| ល.រ. | ក្រុមទំនិញ | អតិផរណាឆ្នាំ២០១៥ | អត្រារួមចំណែក | អតិផរណាឆ្នាំ២០១៤ |
|---|---|---|---|---|
| | ទំនិញប្រើប្រាស់ (២៥៩ មុខ) | ១,២% | ១០០% | ៣,៩% |
| ១ | ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ | ៤,៦% | ៦,១% | ៥,៧% |
| ២ | ភោជនីយដ្ឋាន | ៤,៥% | ២២% | ៧% |
| ៣ | ម្ហូបអាហារ | ៤,១% | ១៤៦% | ៤,៩% |
| ៤ | សម្លៀកបំពាក់ និងស្បែកជើង | ៣,៦% | ៨,៩% | ២,២% |
| ៥ | គ្រឿងសង្ហារឹម និងសម្ភារៈប្រើប្រាស់ | ២,០% | ៤,៥% | ៧,៣% |
| ៦ | ការកម្សាន្ត និងវប្បធម៌ | ១,៩% | ៤,៦% | ៣,៥% |
| ៧ | សុខាភិបាល | ០,៧% | ២,៨% | ៤,៣% |
| ៨ | ការសិក្សា | ០,០% | ០,០% | ៥,៣% |
| ៩ | ទូរគមនាគមន៍ | -១,២% | -១,១% | -២,៧% |
| ១០ | ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ទនៈផ្សេងៗ | -៣,៥% | -៤៩% | ២,៨% |
| ១១ | ទំនិញ និងសេវាកម្មផ្សេងៗ | -៣,២% | -៥,៩% | -៣,៧% |
| ១២ | ការដឹកជញ្ជូន<br>ក្នុងនោះប្រេងសាំង | -៩,២%<br>-២២,១% | -៩៣%<br>-៩០% | -១,០%<br>-៣,០% |

⇨ក្រុមទំនិញដែលមានសន្ទស្សន៍ថ្លៃថយចុះមាន ការដឹកជញ្ជូន ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈផ្សេងៗទូរគមនាគមន៍ និងទំនិញនិងសេវាកម្មផ្សេងៗ។

តារាងខាងក្រោមបង្ហាញអតិផរណាប្រចាំខែ២០១៣-២០១៥( ជាកំណើនថ្លៃទំនិញធៀបនឹងខែដូចគ្នាឆ្នាំមុន )។

| | ធៀបនឹង... | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៥ | ខែដូចគ្នាឆ្នាំ | ០,៤% | ១,៦% | ១,១% | ១,៣% | ១,០% | ០,៧% | ០,៨% | ០,៨% | ០,៩% | ១,៣% | ១,៩% | ២,៨% | ១,២% |
| ២០១៤ | ខែដូចគ្នាឆ្នាំ | ៤,៥% | ៤,៣% | ៥,០% | ៤,៩% | ៤,៦% | ៤,៩% | ៤,២% | ៤,១% | ៣,៦% | ២,៩% | ២,៤% | ១,១% | ៣,៩% |
| ២០១៣ | ខែដូចគ្នាឆ្នាំ | ១,៨% | ១,៧% | ១,០% | ១,០% | ២,៨% | ២,៩% | ៤,០% | ៣,៣% | ៣,៩% | ៤,២% | ៤,២% | ៤,៧% | ៣,០% |

⇨ មុខទំនិញដែលមានការឡើងថ្លៃគួរឲ្យកត់សម្គាល់មាន ត្រីស្រស់៨,៣% បន្លែ៧,៦% សាច់ជ្រូក៣,៦% ផ្លែឈើ៣,៣% និងសាច់គោស្រស់ ៣,១% ។

➢**អត្រាប្តូរប្រាក់:**

⇨ជារួមប្រាក់រៀលមានការឡើងថ្លៃធៀបនឹងរូបិយប័ណ្ណបរទេស។ នាចុងឆ្នាំ២០១៥ អត្រាប្តូរប្រាក់រៀលធៀបនឹងរូបិយប័ណ្ណមួយចំនួនមានស្ថានភាពដូចខាងក្រោម:

- ប្រាក់រៀលឡើងថ្លៃ**០,៦%**ធៀបនឹងដុល្លារអាមេរិក និងមានអត្រា៤០៥០៛/ដុល្លារ
- ប្រាក់រៀលឡើងថ្លៃ**៩,៧%** ធៀបនឹងបាតថៃ និងមានអត្រា១១២៛/បាត
- ប្រាក់រៀលឡើងថ្លៃ **៥,២%** ធៀបនឹងដុងវៀតណាម និងមានអត្រា០,១៨១៛/ដុង។

## ២) ស្ថានភាពថវិកាជាតិ

➢យោងតាមស្ថិតិដែលឆ្លងកាត់រតនាគារជាតិ ចំណូលថវិកាជាតិក្នុងឆ្នាំ២០១៥នេះ អនុវត្តបានចំនួន ១២០២១,៧ប៊ីលានរៀល ស្មើនឹង ១០៥% នៃផែនការ ក្នុងនោះចំណូលចរន្ត ១១៧៥៧,១ប៊ីលានរៀល ស្មើនឹង ១០៦% នៃផែនការ និងចំណូលមូលធន២៦៥,១ប៊ីលានរៀល។



➢ បើធៀបនឹងឆ្នាំ២០១៤ ចំណូលថវិកាជាតិកើនឡើង ១០% ក្នុងនេះ ចំណូលចរន្តកើនឡើង១០% និងចំណូលមូលធនកើនឡើង៣២%។

⇨ការកើនឡើងនៃចំណូលចរន្តជាចម្បងបណ្តាលមកពីចំណូលសារពើពន្ធកើនឡើង ១២%។

| មុខចំណូល | ផែនការ | %Δធៀបនឹងឆ្នាំ២០១៤ | មុខចំណូល | ផែនការ | %Δធៀបនឹងឆ្នាំ២០១៤ |
|---|---|---|---|---|---|
| **ចំណូលសារពើពន្ធ** * | ១០៩% | +១២% | **ចំណូលមិនមែនសារពើពន្ធ** * | ៦០% | -៧% |
| ✓**ពន្ធ និងអាករគយ** ** | ១២២% | +១៧% | ✓នេសាទ | ៧៤% | -១៦% |
| –ពន្ធគយ (របបនាំចូល) | ១១៧% | +១៥% | ✓ រុក្ខាប្រមាញ់ | ៤៦% | -៦០% |
| –អាករពិសេសលើរបបនាំចូល | ១៤២% | +៣២% | ✓សម្បទានរ៉ែ | ៣៧% | +៨៨% |
| –អាករលើតម្លៃបន្ថែមរបបនាំចូល | ១១៨% | +១៣% | ✓អាកាសចរណ៍ស៊ីវិល | ១១៧% | +៧% |
| –អាករនាំចេញ | ៣១% | -៥២% | ✓ ផលទុនទេសចរណ៍ | ៥៣% | +២% |
| –អាករបន្ថែមលើតេលសិលា | ១១០% | ១១% | ✓ប្រៃសណីយ៍ និងទូរគមនាគមន៍ | ១១៥% | +៥៦% |
| ✓**ចំណូលពន្ធដារ** *** | ១១២% | +២៣% | (១) | ៧៨% | +៣៣% |
| –ពន្ធលើប្រាក់បៀវត្ស | ១២០% | +១៩% | ✓អាករស្ពានទូត | ៩៤% | -១% |
| – ពន្ធលើប្រាក់ចំណេញ | ១១៨% | +២៧% | ✓ ត្រួតពិនិត្យគុណភាពផលិតផល | ៨% | -១០% |
| – ពន្ធលើឈ្នួលផ្ទះ–ដី | ១៤១% | +៣១% | ✓ ជួលរោងចក្រ សហគ្រាសសម្ភារៈ | | -១០០% |
| – អាករលើផលរបរ | ៨២% | +៦% | ✓ឯកជនភាវូបនីយកម្ម | | -៩៤% |
| – អាករលើតម្លៃបន្ថែម | ១០០% | +១៣% | ✓ ការលក់អចលនកម្ម | | |
| –អាករពិសេស | ៩៣% | +១៦% | | | |
| –ពន្ធថវិកាខេត្តរាជធានី | ១២០% | +៣៥% | | | |
| ✓**ចំណូលសារពើពន្ធផ្សេងៗ** * | ១១០% | +១៧% | | | |
| –ចំណូលពីកាស៊ីណូ | ១៤៩% | +៤៧% | | | |
| –ចំណូលពីអាជ្ញាបណ្ណក្នុងស្រុក | ៧៣% | +១% | | | |
| –កម្រៃការគ្រប់គ្រង និងទិដ្ឋាកានាំចេញ | ៩០% | -៣% | | | |

** តួលេខរតនាគាជាតិ* ***តួលេខអគ្គនាយកដ្ឋានគយនិងរដ្ឋាករ* ****តួលេខអគ្គនាយកដ្ឋានពន្ធដារ*

➢ចំណាយថវិកាជាតិក្នុងឆ្នាំ២០១៥ អនុវត្តបាន៩១៥៨ប៊ីលានរៀល ស្មើនឹង ៨១% នៃផែនការ ក្នុងនោះ ចំណាយចរន្ត ៦៧២១,៧ប៊ីលានរៀលស្មើនឹង ៨២% នៃផែនការ និងចំណាយមូលធន ១៥៣៦,៣ប៊ីលានរៀល។

➢បើធៀបនឹងឆ្នាំមុន ចំណាយថវិកាជាតិកើនឡើង ៦%ក្នុងនោះចំណាយចរន្តកើនឡើង ៧% និងចំណាយមូលធនកើនឡើង ១%។

➢ជាលទ្ធផល ថវិកាជាតិនាឆ្នាំ២០១៥ មានអតិរេកចំនួន ១០៧៥,៩,៤ប៊ីលានរៀល។ ប៉ុន្តែគួរកត់សម្គាល់ថាតួលេខចំណាយមូលធនក្នុងតារាងទិន្នន័យឆ្លុះបញ្ចាំងតែចំណាយដែលបានឆ្លងកាត់រតនាគារជាតិតែប៉ុណ្ណោះ។

### ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➢សេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០១៥មានសូចនាកររូបិយវត្ថុដូចខាងក្រោម:

⇨រូបិយវត្ថុ *M2* មានចំនួន៤៨៨២៣ប៊ីលានរៀល កើនឡើង១៤,៧% ធៀបនឹងឆ្នាំ២០១៤។

**សមាសធាតុរូបិយវត្ថុ ឆ្នាំ២០១៥**(% នៃរូបិយវត្ថុទូទៅ*M2*)




**សមាសធាតុរូបិយវត្ថុ ឆ្នាំ២០១៤**




⇨សមាសធាតុរូបិយវត្ថុមិនសូវមានការប្រែប្រួលគួរឲ្យចាប់អារម្មណ៍។ រូបិយវត្ថុក្រៅធនាគារថយចុះពី១៣,១%នៃM2 ក្នុងឆ្នាំ២០១៤ មក ១២,១% នៃM2ក្នុងឆ្នាំ២០១៥ ឯប្រាក់បញ្ញើជារូបិយបណ្ណបរទេសកើនឡើងពី ៨២,៨% ទៅ ៨៣,0% នៃM2។

⇨តារាងខាងក្រោមបង្ហាញកំណើនសូចនាកររូបិយវត្ថុធៀបនឹងឆ្នាំមុន (២០១១-២០១៥)

| | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|---|---|
| *M2* | +២១% | +២១% | +១៥% | +២៩,៩% | +១៤,៧% |
| *M1* | +២៣% | +២% | +២១% | +២៩,៣% | +៦,៩% |
| រូបិយវត្ថុក្រៅធនាគារ | +២២% | 0 | +១៩% | +២៥,៦% | +៥,៤% |
| ប្រាក់បញ្ញើចរន្ត | +៥១% | +៥៧% | +៤៦% | +៦៨,៥% | +១៨,១% |
| រូបិយវត្ថុផ្សេងៗ | +២១% | +២៥% | +១៤% | +៣០% | +១៦,១% |
| ប្រាក់បញ្ញើមានកាលកំណត់និងសន្សំ | +៣៦% | +៤០% | +២១% | +១៥,៣% | +៤២,២% |
| ប្រាក់បញ្ញើជារូបិយបណ្ណ | +២១% | +២៤% | +១៣% | +៣០,៥% | +១៥,៣% |

⇨ក្នុងឆ្នាំ២០១៥ រូបិយវត្ថុទូទៅ*M2*មានចំនួនប្រហែល ៦៥%នៃផសស ប៉ុន្តែ**សមមាត្រ***M1*ក្នុងផសស មានត្រឹមតែ ៩,0% ប៉ុណ្ណោះ។ ក្នុងអំឡុងពេល៥ឆ្នាំចុងក្រោយរូបិយវត្ថុក្រៅធនាគារ ប្រាក់បញ្ញើចរន្ត និងប្រាក់បញ្ញើជារូបិយបណ្ណមានកំណើនយឺត ប៉ុន្តែប្រាក់បញ្ញើមានកាលកំណត់និងសន្សំមានការកើនឡើងគួរឲ្យកត់សម្គាល់។

➢ទុនបំរុងជារូបិយប័ណ្ណបរទេសសុទ្ធ មានចំនួន៤៩៩៨លានដុល្លារ កើនឡើង ១៦,៤% ធៀបនឹងឆ្នាំ២០១៤។

➢ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅ**ធនាគារជាតិនៃកម្ពុជា** មានចំនួន១៥៧០៨ ប៊ីលានរៀលកើនឡើង ៣០,៨% បើធៀបនឹងឆ្នាំមុន។

➢ឥណទានផ្តល់ដោយធនាគារពាណិជ្ជមានចំនួន៤៧៩៤៦ប៊ីលានរៀល កើនឡើង ២៣,៤% ធៀបនឹងឆ្នាំមុន។

➢ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានចំនួន ១២១៣១ប៊ីលានរៀល កើនឡើង ៤៧,៦% ធៀបនឹងឆ្នាំមុន។

➢អត្រាការប្រាក់ប្រចាំឆ្នាំ:

| *ប្រភេទអត្រាការប្រាក់* | *អត្រាឆ្នាំ២០១៥* | *អត្រាឆ្នាំ២០១៤* | %Δ (២០១៥/២០១៤) |
|---|---|---|---|
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៦,៦៤% | ៦,០៨% | +១០,៤% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១៦,២៤% | ១៦,២៦% | -០,១% |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,៤៥% | ៤,២៣% | +៥,២% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១១,៦% | ១១,៥១% | +០,៨% |
| កម្ចីជារៀលនៅហត្ថកសិករ | ៣១,២% | ៣១,២% | ០% |
| កម្ចីជារៀលនៅអម្រឹត | ៣០% | ៣១,៨% | -៥,៧% |
| កម្ចីជារៀលនៅស្ថាបនា | ៣០% | ៣១,២% | -៣,៨% |
| កម្ចីជារៀលនៅប្រាសាក់ | ២២,៨% | ២៥,៨% | -១១,៦% |

## ៤) ស្ថានភាព កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➢*កសិកម្ម:*

⇨ក្នុងពេលនេះមិនទាន់មានតួលេខផលិតផលស្រូវប្រចាំឆ្នាំ២០១៥នៅឡើយ (ក្នុងតារាងមានត្រឹមឆមាសទី១)







⇨ក្នុងឆ្នាំ២០១៥ ផលិតផលកៅស៊ូមានចំនួន១២៦,៨ពាន់តោន កើនឡើង ៣០,៧% ធៀបនឹងឆ្នាំ២០១៤។ ផ្ទៃដីចៀរជ័រមានចំនួន១១១,២ ពាន់ហិកតាកើនឡើង ២២,៧%ធៀបនឹងឆ្នាំ២០១៤ និងផ្ទៃដីដាំដុះសរុបមាន ៣៨៩ ពាន់ហិចតាកើនឡើង ៨,៧%ធៀបនឹងឆ្នាំ២០១៤។

⇨ ផលិតកម្មនេសាទឆ្នាំ២០១៥ មានចំនួន ៦៨៩,៧ ពាន់តោនមានការកើនឡើង ២%ធៀបនឹងឆ្នាំ២០១៤។

➢*ឧស្សាហកម្ម*

⇨ផលិតកម្មវាយនភណ្ឌនិងស្បែកជើងសម្រេចបាន៦៣៥,៨លានដុល្លារកើនឡើង១៦%។

⇨ទឹកស្អាតផ្គត់ផ្គង់ដោយរដ្ឋាករទឹកមានចំនួន ២១៨លានម៣កើនឡើង១៦%។

⇨ **ការចុះបញ្ជី ការបើកថ្មី និងការបន្ត រោងចក្រ សហគ្រាស នៅក្រសួងឧស្សាហកម្ម:**

| *ប្រភេទ* | *ចំនួន :២០១៥* | *ចំនួន:២០១៤* | %Δ |
|---|---|---|---|
| ចំនួនរោងចក្រសរុប | ១៤៥០ | ១២៨៦ | +១៣% |
| រោងចក្រថ្មី ដែលបានចុះបញ្ជី | ១៦០ | ១៩៧ | -១៩% |
| ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | - | ១៥៦ | - |
| ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | - | - | - |

➢ ***រ៉ែនិងថាមពល:***

ថាមពលអគ្គិសនីផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ៥៨១៥,៩GWh កើនឡើង២៧%។ ក្នុងនោះវារីអគ្គិសនីមានចំនួន២១៥៣,១GWh កើនឡើង១៧% ធ្យូងថ្មចំនួន២១៤៥,៣GWh កើនឡើង១៥៨% នាំចូលពីប្រទេសជិតខាងចំនួន១៣៤៨,៤ GWh ថយចុះ១៧% ធៀបនឹងឆ្នាំ២០១៤។

➢**សំណង់ (ការអនុញ្ញាត):**

▪ការអនុញ្ញាតឲ្យសាងសង់ឆ្នាំ២០១៥ មានទឹកប្រាក់ស្មើនឹង ៣៣៣៨,១លានដុល្លារ កើនឡើង៣៣% ធៀបនឹងឆ្នាំ ២០១៤។

| *ប្រភេទសំណង់* | ពាន់ម$^2$ :២០១៥ | ពាន់ម$^2$ :២០១៤ | % ∆ |
|---|---|---|---|
| លំនៅឋាន | ៤៣៤៣,២ | ៣១៦៥,៧ | +៣៧% |
| ឧស្សាហកម្ម | ១៨៩៥,៦ | ១៧២៥,៩ | +១០% |
| ពាណិជ្ជកម្ម | ១០៩៨ | ៩៧៧,៤ | +១២% |
| ទេសចរណ៍ | ៣០៦,២ | ៣១៥,២ | -៣% |
| … | … | … | … |
| អនុញ្ញាតសរុប | ៧៧៧៧,១ | ៦៤៦០,២ | +២០% |

▪ ក្នុងការអនុញ្ញាតនេះ សំណង់ដែលពេញនិយមមាន លំនៅឋាន (៥៥,៨%នៃផ្ទៃក្រឡាសរុប) និងឧស្សាហកម្ម (២៤,៤% នៃផ្ទៃក្រឡាសរុប)។

▪**ការងារ:**

| *ប្រភេទ* | ២០១៥ (នាក់) | ២០១៤ (នាក់) | %∆ |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារធ្វើ(ទីភ្នាក់ងារជាតិមុខរបរនិងការងារ) | ៩៥១៧ | ២៥៦៩២ | -៦៣% |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ៨៥០៧៣ | ៧១៥៨២ | +១៩% |
| អ្នកទទួលបានការងារក្នុងប្រទេស | ៥៨៨០១ | ៤៧៤៤៣ | +២៤% |
| អ្នកទទួលបានការងារក្រៅប្រទេស | ២៦២៦៧ | ២៤១៣៩ | +១០% |

▪**វិនិយោគ**:គម្រោងវិនិយោគអនុញ្ញាតដោយ គ.វ.ក./ក.អ.ក./គ.ជ.នា ក្នុងឆ្នាំ២០១៥ (ថ្មី និងពង្រីក) មានចំនួន ១៨១ គម្រោង។ ជាទុនវិនិយោគមានទឹកប្រាក់ **៤៦៤៣,៦**លានដុល្លារ និងអាចផ្តល់ការងារបាន ១៩៦ពាន់នាក់។

| *ប្រភេទ* | *២០១៥* | *២០១៤* | %∆ |
|---|---|---|---|
| **អនុញ្ញាតសរុប (លានដុល្លារ)** | ៤៦៤៣,៦ | ៣៩២៦,៤ | +១៨% |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ៤៨២,៦ | ២៦៤,៧ | +៨២% |
| វិស័យឧស្សាហកម្ម<br>(ក្នុងនោះក្នុងតំបន់សេដ្ឋកិច្ចពិសេស) | ៩១៩,៣<br>(១១៤,៦) | ២៨២៨,៦<br>(២០៣៩,៤) | -៦៨%<br>(-៩៤%) |
| វិស័យទេសចរណ៍ | ១១១,៩ | ៤៧៩,៦ | -៧៧% |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ៣១២៩,៨ | ៣៥៣,៥ | +៧៨៥% |
| **ចំនួនគម្រោងថ្មីនិងពង្រីក (ចំនួន)** | ១៨១ | ២១០ | -១៤% |
| **ចំនួនពលករ (ពាន់នាក់)** | ១៩៦ | ២៥១,២ | -២២% |

▪ *សេវាកម្មនិងទេសចរណ៍:*

➢ **ការចុះបញ្ជីនិងលុបចេញពីបញ្ជី**

| *ប្រភេទ* | ២០១៥ ( *ចំនួន* ) | ២០១៤( ចំនួន ) | %Δ |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ៤៤៩០ | ៣៩០៥ | +១៥% |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ៤៧ | ៦៥ | -២៨% |
| ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | ១៧០៧ | ៤១២៧ | -៥៩% |

➢ **ទំនិញឆ្លងកាត់កំពង់ផែ** ( សរុប៦កំពង់ផែ )មានចំនួន ៨៦៥៤ពាន់តោនកើនឡើង៦%។ ក្នុងនោះ:

| *ប្រភេទ* | ២០១៥ ( ពាន់តោន ) | ២០១៤( ពាន់តោន ) | %Δ |
|---|---|---|---|
| កំពង់ផែភ្នំពេញ | ២១៨២,៨ | ១៩០៣ | +១៥% |
| កំពង់ផែកំពង់សោម | ៤៩៨០,៤ | ៣៩០៩ | +២៧% |
| កំពង់ផែស្រែអំបិល និងកោះកុង | ៥៧៤,៩ | ១១៥៨ | -៥០% |
| កំពង់ផែឧកញ៉ាម៉ុង | ៩១៥,៩ | ១២១៧ | -២៥% |

➢ **ប្រៃសណីយ៍និងទូរគមនាគមន៍**

| *ប្រភេទ* | ២០១៥ | ២០១៤ | %Δ |
|---|---|---|---|
| បញ្ញើក្នុងប្រទេស( ពាន់កញ្ចប់ ) | ១៤៦,៤ | ១៦៥,៦ | -១១,៦% |
| ក្នុងនោះទទួល | ២៣,៧ | ២២,២ | +៦,៦% |
| បញ្ញើក្រៅប្រទេស( ពាន់កញ្ចប់ ) | ១២៤១,៦ | ១៣៧១,៧ | -៩,៥% |
| ក្នុងនោះទទួល | ៥៤១ | ៥១៥,៨ | +៥% |
| សន្ទនាទូរសព្ទក្នុងប្រទេស( ពាន់នាទី ) | ៤០៤០២,៩ | ៤៨០៤៩,៧ | -១៦% |
| ក្នុងនោះហៅចូល | ១១២៦៩,៦ | ១២៨៥៤,៥ | -១២% |
| សន្ទនាទូរសព្ទក្រៅប្រទេស( ពាន់នាទី ) | ១៤៥៩៩១,៦ | ២០២៩៦៣,៨ | -២៨% |
| ក្នុងនោះហៅចូល | ១៤៥១៧២ | ២០១០៣៩,៤ | -២៨% |

➢ **អ្នកដំណើរតាមផ្លូវអាកាស និងទេសចរណ៍**

| *ប្រភេទ* | ២០១៥ ( ពាន់នាក់ ) | ២០១៤( ពាន់នាក់ ) | %Δ |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ១៦៤,៦ | ១៤៨ | +១២% |
| អ្នកដំណើរតាមផ្លូវអាកាស ( ក្នុងស្រុក ) | ៤៣៦,២ | ២៩៩ | +៤៦% |
| អ្នកដំណើរតាមផ្លូវអាកាស ( អន្តរជាតិ ) | ៥៦០៦,៣ | ៥១៦៩ | +៨% |
| អ្នកទេសចរជាតិចេញក្រៅប្រទេស | ១១៩៤ | ៩៦៦ | +២៥% |
| អ្នកទេសចរអន្តរជាតិមកកម្ពុជា | ៤៧៧៥,២ | ៤៤៩០ | +៦% |
| ✓តាមផ្លូវអាកាស | ២៤៧៦ | ២២៦២ | +៩% |
| ✓ តាមផ្លូវគោក និងទឹក | ២២៩៩,២ | ២២២៨ | +៣% |

## ៥) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

▪យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ ការនាំចូលក្នុងឆ្នាំ២០១៥ មានចំនួន ៤៩៨០១,៣ប៊ីលានរៀលថយចុះឡើង ១៧% បើធៀបនឹងឆ្នាំ ២០១៤ក្នុងនោះ ៖

| មានការថយចុះ | មានការកើនឡើង |
|---|---|
| ប្រេងខ្មៅ -៥២% | ប្រេងសាំង +១៣% |
| គ្រាក់ទ័រនិងគោយន្ត-៣៧% | ប្រេងម៉ាស៊ូត +៧% |
| ប្រេងឆា-២៤% | ឧស្ម័ន +៥៧% |
| សំលៀកបំពាក់ចាស់-១៤% | ដែកសំណង់+៥២% |
| ស៊ីម៉ងត៍-១១% | ស៊ីម៉ង់+៣៧% |
| ជីនិងថ្នាំកសិកម្ម-៧% | រថយន្តសរុប (ជាសាច់ប្រាក់) +២៦% |
| អនុញ្ញាតិនាំចូលក្នុងក្របខ័ណ្ឌវិនិយោគសាធារណៈ-១៧% | គ្រឿងអេឡិចត្រូនិច+៥៦% |
| អនុញ្ញាតិនាំចូលក្នុងក្របខ័ណ្ឌវិនិយោគឯកជន-១១% | ម៉ូតូ+៩% |
| | អង្ករ+៨៦% |
| | ប៊ីចេង+៤% |
| | ផ្លែឈើនិងបន្លែ+២៥% |
| | ភេសជ្ជៈ +១១% |
| | នាំចូលក្នុងក្របខ័ណ្ឌច្បាប់វិនិយោគ +១៣% |

▪**ការនាំចេញ**ឆ្នាំ២០១៥មានចំនួន៣៧៧២៦ប៊ីលានរៀលកើនឡើង១៥%ធៀបនឹងឆ្នាំ២០១៤ក្នុងនោះ៖

| ទំនិញ | %∆ធៀបនឹង-២០១៤ | ទំនិញ | %∆ធៀបនឹង-២០១៤ |
|---|---|---|---|
| ផលិតផលឈើកែច្នៃ | -៧២% | ផលិតផលនេសាទ | -៦៣% |
| វាយនភណ្ឌនិងស្បែកជើង | +១២% | កៅស៊ូ | +៣០% |
| អង្ករ | +៤០% | | |

▪ក្នុងឆ្នាំ២០១៥ ជញ្ជីងពាណិជ្ជកម្មមានឱនភាពចំនួន *១២០៧៥ប៊ីលានរៀល ស្មើនឹង* ៣០១៨,៧លានដុល្លារ ។

## ៦) ការប្រែប្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងឆ្នាំ២០១៥នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជា បង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖

| សូចនាករ | បម្រែបម្រួលធៀបនឹងឆ្នាំ ២០១៤ | ផ្សេងៗ |
|---|---|---|
| ១. អតិផរណារ | +១,២% | មានកម្រិតទាប |
| ២. ថ្លៃត្រីស្រស់ | +៨,៣% | កើនឡើងខ្ពស់មិនឈប់ឈរ |
| ៣. ថ្លៃបន្លែ | +៧,៦% | កើនឡើងខ្ពស់មិនឈប់ឈរ |

## ៧) សេចក្តីសន្និដ្ឋាន

១)-អត្រាអតិផរណាប្រចាំឆ្នាំ២០១៥ មានកម្រិតទាប ប៉ុន្តែមុខទំនិញសំខាន់ៗមួយចំនួនដូចជា ត្រីស្រស់ បន្លែ និងសាច់ជ្រូក ដែលបម្រើអោយជីវភាពប្រចាំថ្ងៃមានការឡើងថ្លៃគួរឲ្យបារម្ភណ៍។

២)-បច្ចុប្បន្នបញ្ហាគុណភាពសេវាសុខាភិបាលកំពុងតែមានការចាប់អារម្មណ៍យ៉ាងខ្លាំងពីសាធារណៈជន។ កត្តានេះបានកើតឡើងដោយមូលហេតុមួយចំនួនដូចខាងក្រោមៈ

(ក) គ្រូពេទ្យមួយចំនួនខ្វះក្រមសីលធម៌វិជ្ជាជីវៈ នាំឲ្យបាត់បង់ទំនុកចិត្តពីសាធារណៈជន

(ខ) ខ្វះមធ្យោបាយ សម្ភារៈ ដូចជាមន្ទីរពេទ្យនិងគ្រឿងបរិក្ខារមិនទាន់គ្រប់គ្រាន់។

ដើម្បីដោះស្រាយបញ្ហានេះគួរតែមានការយកចិត្តទុកដាក់ៈ

(ក) លើកកម្ពស់គុណភាពសេវា និងក្រមសីលធម៌វិជ្ជាជីវៈ

(ខ) ជំរុញការវិនិយោគសាងសង់មន្ទីរពេទ្យ មជ្ឈមណ្ឌលសុខាភិបាល និងការបណ្តុះបណ្តាលបច្ចេកទេស សុខាភិបាលនិងក្រមសីលធម៌វិជ្ជាជីវៈ។

៣)-ចំណាយថវិកាចរន្តមានកម្រិតទាបបន្តិចបើធៀបនឹងផែនការ (៨២%) ដោយសារការចាប់ផ្តើមអនុវត្ត នីតិវិធីចំណាយថវិកាតាមកម្មវិធី។

៤)-ការផ្គត់ផ្គង់រូបិយវត្ថុ ($M_2$) មានកំណើនទាប ប្រហែល ១៥% ក្នុងនោះរូបិយវត្ថុក្រៅធនាគារមានកំណើន តែ ៥.៤% ប៉ុណ្ណោះ។ ការផ្តល់ឥណទានដោយធនាគារពាណិជ្ជក៏មានកំណើនទាប (២៣,៤%) ធៀបនឹងឆ្នាំ២០១៤ ដែលមានកំណើនស្មើនឹង ៣០,២%។

អង្គប្រជុំបានចាប់អារម្មណ៍អំពីសមមាត្រ$M_1$ដែលមានតែ ៩% នៃផសស តំណាងធនាគារជាតិបានបំភ្លឺថា សមាសធាតុ$M_1$ គឺជារូបិយវត្ថុបោះផ្សាយដែលសម្របតាមតម្រូវការនៃសេដ្ឋកិច្ច។ ការប្រព្រឹត្តទៅនៃ$M_1$ ដូចនេះ ជាការប្រសើរ ដោយហេតុថា រដ្ឋមិនបានបោះផ្សាយរូបិយវត្ថុដើម្បីបំពេញឱនភាពថវិកា។

៥)-អង្គប្រជុំបានចាប់អារម្មណ៍សុំអោយមានការចិញ្ចឹមត្រីឆ្តោនៅក្នុងតំបន់មួយចំនួនដែលមិនពាក់ព័ន្ធនឹងការ យកកូនត្រីមកធ្វើចំណី។ ចំពោះបញ្ហានេះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កំពុងតែធ្វើការសិក្សា។

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា
## ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមករា ឆ្នាំ២០១៦

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | **០៥/០១/១៦ ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវស្ពានអាកាស និងផ្លូវក្រោមដី តិចណូ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង សម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅរាជធានីភ្នំពេញ។ |
| ២ | **០៦/០១/១៦ ម៉ោង១៦:៣០នាទី** | ជួបប្រជុំពិភាក្សាការងារជាមួយតំណាងក្រុមហ៊ុន Union Development Group នៅបន្ទប់ឯកឧត្តម ប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | **០៧/០១/១៦ ម៉ោង០៨:០០នាទី** | ចូលរួមជាគណៈអធិបតី ក្នុងពិធីមីទិញអបអរសាទរបុណ្យខួបអនុស្សាវរីយ៍លើកទី៣៧ ទិវាមហាជ័យជំនះ ៧ មករា (០៧.០១.១៩៧៩-០៧.០១.២០១៦) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជាប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តតាកែវ និង លោកជំទាវ នៅសាលមហោស្រពខេត្តតាកែវ។ |
| ៤ | **០៩-១០/០១/១៦ ព្រឹក-ល្ងាច** | ចូលរួមសន្និបាតគណៈកម្មាធិការកណ្តាលលើកទី៣៩ អាណត្តិទី៥ របស់គណបក្សប្រជាជនកម្ពុជា នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |
| ៥ | **១៣/០១/១៦ ម៉ោង០៩:៣០នាទី** | ដឹកនាំកិច្ចប្រជុំគណៈកម្មការសម្របសម្រួលជាមួយភាគីចិន ជាមួយក្រុមហ៊ុន Guandong Foreign Construction ដើម្បីពិនិត្យលើការងារសាងសង់ និងការសុំពន្យារពេលដល់ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៦ សម្រាប់អគារមជ្ឈមណ្ឌលព័ត៌មាន និងបច្ចេកវិទ្យារបស់ទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៦ | **១៥/០១/១៦ ម៉ោង០៨:៣០នាទី** | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការគ្រប់គ្រងលើការវាស់វែងនិងការផលិតផែនទី និងលើអាជីវកម្ម វាស់វែង និងការផលិតផែនទី។<br>២-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនី និងអេឡិចត្រូនិក។<br>៣-បញ្ហាផ្សេងៗ។<br>នៅទីស្តីការនាយករដ្ឋមន្ត្រី។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា
## ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមករា ឆ្នាំ២០១៦ (តចប់)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៧ | **១៩/០១/១៦ ម៉ោង០៨:៣០នាទី** | ចូលរួមក្នុងកិច្ចប្រជុំផ្សព្វផ្សាយខ្លឹមសារ នៃសន្និបាតគណៈកម្មាធិការកណ្តាលលើកទី៣៩ អាណត្តិទី៥ ដើម្បីអនុវត្តផែនការដាក់ស្តែងនៅគ្រប់មូលដ្ឋានទូទាំងខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** សមាជិកគណៈអចិន្ត្រៃយ៍ គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជាប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តតាកែវ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៨ | **២០/០១/១៦ ម៉ោង០៩:០០នាទី** | ដឹកនាំកិច្ចប្រជុំ ដើម្បីស្តាប់របាយការណ៍ចុងក្រោយរបស់ក្រុមហ៊ុន Green Goal ស្តីពីផែនការដោះស្រាយ ផលប៉ះពាល់សម្រាប់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ លើការងារដោះស្រាយផលប៉ះពាល់គម្រោងពង្រឹងតំបន់សុវត្ថិភាព និងសន្តិសុខនៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៩ | **២១/០១/១៦ ម៉ោង១៥:៣០នាទី** | ដឹកនាំកិច្ចប្រជុំគណៈកម្មការតាមដាន និងត្រួតពិនិត្យលើការសាងសង់អាកាសយានដ្ឋានអន្តរជាតិ ប្រចាំខែធ្នូ ឆ្នាំ២០១៥ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១០ | **២៥/០១/១៦ ម៉ោង០៨:៣០នាទី** | ចូលរួមក្នុងវេទិកាស្រូវអង្ករកម្ពុជាលើកទី៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារសុខាភ្នំពេញ។ |
| ១១ | **២៩/០១/១៦ ម៉ោង១១:០០នាទី** | ជួបប្រជុំពិភាក្សាការងារជាមួយឯកឧត្តម **ម៉ិច សុខា** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |

# ព្រឹត្តិបត្រព័ត៌មាន



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in